## ស្ត្រីគួរមានក្តីប្រាថ្នាខ្ពស់

វិធានការការពារដ៏តូចមួយគឺៈ *ការលុបបំបាត់ការជួញដូរស្ត្រីនៅកម្ពុជា*

ការជួញដូរ នារី និងស្ត្រី គឺជាបញ្ហាមួយក្នុងបញ្ហាដ៏ខ្លាំងក្លាបំផុតនៃការរំលោភសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាកំពុងប្រឈមមុខក្នុងពេលបច្ចុប្បន្ន ។ នៅក្នុងប្រទេសមួយដែលប្រជាពលរដ្ឋ មានប្រាក់ចំណូលទាបជាងគេបំផុតក្នុងចំណោមបណ្តាប្រទេសក្រីក្រ លើពិភពលោក ហើយប្រព័ន្ធឧបត្ថម្ភរបស់រដ្ឋមិនត្រូវបានគេលើកស្ទួយ ជនរងគ្រោះច្រើនហួសការរំពឹងទុក ត្រូវបានបោកបញ្ឆោតលួងលោមថា នឹងរកការងារឱ្យធ្វើ រួចបង្ខំអោយបំរើការងារ ផ្លូវភេទ ឬក៏ធ្វើអាជីវកម្មកេងប្រវ័ញ្ចយកផលចំណេញពីការងារ ។ ជនរងគ្រោះទាំងនោះត្រូវបានគេឃុំឃាំង ដោយប្រើការគំរាមកំហែង ការបោកបញ្ឆោត ការប្រើប្រាស់គ្រឿងញៀន ការបង្ខំដល់រាងកាយ ហើយនិងតែងតែត្រូវបានគេឃុំឃាំង ទុកដូចជាខ្ញុំបំរើ ។ គោលបំណងកម្មវិធីស្ត្រីគួរមានក្តីប្រាថ្នាខ្ពស់ របស់អង្គការជំនួយជប៉ុន និងអាមេរិកដល់ប្រទេសកម្ពុជា（JRfC/AAfC） គឺដើម្បីការពារទប់ស្កាត់កុំអោយមានការជួញដូរនារី និងស្ត្រីកម្ពុជាពីការបំរើការងារផ្លូវភេទ និងការកេងប្រវ័ញ្ចពលកម្ម តាមរយៈកម្មវិធីលើកទឹកចិត្តមួយ សំរាប់អោយ ស្ត្រីនានា ដែលមកពីគ្រួសារជួបប្រទះភាពក្រីក្រ ដើម្បីស្នាក់នៅក្នុងសាលារៀន ហើយបានទទួលការហ្វឹកហ្វឺនវិជ្ជាជីវៈបន្ថែម ដើម្បីឱ្យពួកគេអាចរកការងារធ្វើបាន រកប្រាក់ចំណូល ហើយនិងជួយពួកគេឱ្យមាន សិទ្ធិស្មើគ្នាក្នុង ការរស់នៅក្នុងសង្គម និងនៅក្នុងឆាកនយោបាយ ។

ក្នុងចំណោមជនរងគ្រោះនៃការជួញដូរផ្លូវភេទ ក្រុមភាគច្រើនដែលងាយរងគ្រោះជាងគេ គឺជាស្ត្រីដែលមិនចេះអក្សរ ពួកគេត្រូវបានគេបោកបញ្ឆោតឱ្យធ្វើអន្តោប្រវេសន៍ ហើយពួកគេកំពុងតែត្រូវបានគេកេងប្រវ័ញ្ចហើយក៏ជាគោលដៅសំរាប់គេធ្វើអាជីវកម្មដែរ ។ កម្មវិធីរបស់យើងមានទិសដៅ បង្កើនការយកទុកដាក់ក្នុងចំណោមស្ត្រីដែលស្ថិតក្នុងគ្រោះថ្នាក់ ដោយផ្តល់ពួកគេនូវ ជំរើសនានា ដែលប្រហាក់ប្រហែលទៅនឹងផ្ទះពួកគេដែរ ហើយនិងមធ្យោបាយនានា ដែលអាចជួយបង្កើនការរស់នៅរបស់ពួកគេ ។ កម្មវិធីនារីត្រូវមានអនាគតល្អ នឹងត្រូវបើកអោយដំណើរការចេញពីគំរោងអភិវឌ្ឍន៍សាលារៀនតាមជនបទ របស់អង្គការជំនួយជប៉ុន និងអាមេរិកដល់ប្រទេសកម្ពុជា（ JRfC/AAfC ）ដែលបច្ចុប្បន្ននេះបានសាងសង់សាលារៀនចំនួន ៣១០ខ្នង ដែលមានកំរិតបឋមសិក្សា និងអនុវិទ្យាល័យនៅក្នុងភូមិនានា នៅតាមជនបទ（www.cambodiaschools.com）។ គំរោង សាងសង់សាលារៀនតាមជនបទ ដែលបានបើកយុទ្ធនាការនៅឆ្នាំ ១៩៩៩ តាមរយៈថវិកា/មូលនិធិ ពី សប្បុរសជនបរទេសហើយ និងប្រាក់បដិភាគពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី គឺជាកម្មវិធីកសាងសាលារៀនតាមជនបទនៅក្នុងប្រទេសកម្ពុជា ដែលសហការជាមួយ និងក្រសួងអប់រំ នៃព្រះរាជាណាចក្រកម្ពុជា ។ កម្មវិធីសិក្សារបស់គំរោងគឺគោរពទៅតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ ក៏ប៉ុន្តែសាលារៀនយើងជាច្រើនត្រូវបានបន្ថែមគុណភាពអប់រំ ដូចជាការភ្ជាប់អ៊ិនធឺណែត ការបង្រៀនភាសាអង់គ្លេស និងកុំព្យូទ័រ ហើយនិងការបង្រៀនកសិកម្ម ។ បច្ចុប្បន្ននេះយើងបានបំពាក់ថាសផ្កាយរណបជាច្រើននៅតាមបណ្តាសាលារៀនរបស់យើង ដើម្បីផ្តល់ការភ្ជាប់អ៊ិនធឺណែតទៅដល់សាលារៀននានា ដែលដាច់ស្រយាលតាមរយៈ “ប្រព័ន្ធម៉ូតូអ៊ិនធឺណែត” ។

ប្រព័ន្ធម៉ូតូអ៊ិនធឺណែតគឺជាមធ្យោបាយដែលគេរកឃើញថ្មីមួយសំរាប់ការភ្ជាប់អ៊ីមែលទៅតាមភូមិនានាជាកន្លែងដែលគេដ្ឋារចនាសម្ព័ន្ធអ៊ិនធឺណែតមិនមានសោះ ។ រៀងរាល់ព្រឹក ម៉ូតូដែលបំពាក់ដោយម៉ូដឹមគ្មានខ្សែ (Wi-Fi modem) នៅពីខាងក្រោយកែប ដែលផ្ទុកដោយអ៊ីមែល ដែលផ្ញើទៅតាមសាលានានា ដែលនៅតាមផ្លូវចេញពីថាសផ្កាយរណប ដែលគេដាក់តាំងនៅសាលាបង្គោលមួយ (hub school) ។ ម៉ូតូនិមួយៗធ្វើដំណើរទៅកាន់សាលារៀនតាមផ្លូវដែលគេកំណត់ ក៏ត្រូវបានគេបំពាក់ប្រអប់ម៉ូដឹមដែរ នៅពីក្រោយកែប ដែលគេសំរាប់ផ្ទុក ឬបញ្ជូលអ៊ីមែល ។ យើងបានអនុវត្តន៏នូវប្រព័ន្ធនេះ ដោយជោគជ័យនៅតាមភូមិចំនួន ៨ បន្តិចក្រោយមកក៏បានពង្រីករហូតទៅដល់ ភូមិចំនួន ១៥ យើងកំពុងតែឈានទៅភ្ជាប់ភូមិចំនួន ៨0 ហើយនៅពេលឆាប់ៗខាងមុខនេះនឹងមានភូមិចំនួន១៥0 នឹងភ្ជាប់ប្រព័ន្ធម៉ូតូអ៊ិនធឺណែតនេះ ។

គំរោងសាងសង់សាលារៀននៅតាមជនបទ គឺជាគំរោងដ៏ជោគជ័យមួយ ជាពិសេសលើផ្នែកទាក់ទាញឱ្យសិស្សានុសិស្សចូលរៀនបានច្រើនលើសពីមុន និងលើកស្ទួយគុណភាពនៃការអប់រំ ។ ទោះបីជាយ៉ាងនេះក៏ដោយតាមការស្រាវជ្រាវរបស់យើងបានឱ្យដឹងថា សិស្សស្រីៗដែលមករៀននៅសាលានៅមានកំរិតទាប ហើយជាលទ្ធផលពួកគេនៅតែស្ថិតក្នុងភាពអវិជ្ជា ។ ការសិក្សាស្រាវជ្រាវបន្ថែមមួយទៀត បានបង្ហាញឱ្យឃើញថា មូលហេតុសំខាន់ជាងគេ ដែលបណ្តាលអោយកុមារីភាគច្រើនមិនបានចូលរៀន ពីព្រោះមកពីភាពក្រីក្រ ហើយនិងការគាបសង្កត់ពួកគេឱ្យជួយក្រុមគ្រួសារពួកគេ ដូចជាជួយធ្វើស្រែ ជួយមើលប្អូនៗ ហើយនិងចាំផ្ទះ ពេលដែលឪពុកម្តាយពួកគេទៅធ្វើស្រែចំការ ។ យើងបានរកឃើញនឹងបានសម្ភាសន៏កុមារី និងគ្រួសារប្រភេទនេះ នៅក្នុងភូមិចំនួន ៥ ហើយបានឱ្យដឹងថា ពួកគេចង់ទៅរៀនណាស់ ហើយសន្យានឹងទៅរៀន ប៉ុន្តែភ្លាមៗក្រោយមកភាពតានតឹងខាងផ្នែកសេដ្ឋកិច្ចគ្រួសារ ជាទីបញ្ចប់បានបង្ខំឱ្យពួកគេមិនបានចូលរៀនវិញ ។

" **កម្មវិធីស្ត្រីគួរមានក្តីប្រាថ្នាខ្ពស់** " គឺផ្តល់ការលើកទឹកចិត្តដល់នារី និងក្រុមរបស់ពួកគេដើម្បីឱ្យគេអាចចូល រៀនបាន តាមរយៈការផ្តល់ជំនួយជាថវិកាចំនួន ១0$ ក្នុងមួយខែ ឬ ១២0$ ក្នុងមួយឆ្នាំ ដើម្បីឱ្យពួកគេបានចូលរៀន កុំអោយអវត្តមាន ។ ជារៀងរាល់ខែ គ្រូបង្រៀនដែលមើលការខុសត្រូវក្នុងផ្ទះ នឹងផ្ញើអ៊ីមែលមកឱ្យយើងនូវ របាយការណ៍ស្តីពីការសិក្សារបស់នារីៗ ដែលយើងឧបត្ថម្ភ ។ គណនេយ្យកររបស់យើងនឹងត្រូវអនុញ្ញាតឱ្យបើកលុយភ្លាមៗចំនួន ១0$ ទៅឱ្យក្រុមគ្រួសារ បើសិននារីនោះបានចូលរៀន ដោយឥតឈប់សោះ ។ ប្រសិនបើនារីនោះ អវត្តមាន នាងនឹងមិនបានប្រាក់ប្រចាំខែ ព្រោះនាងអវត្តមាន ហើយយើងនឹងចុះទៅមើលថា ហេតុអ្វីបានជានាងមិនបានមករៀន ។ ប្រសិនបើជាករណីឈឺស្កាត់ យើងមិនកាត់ប្រាក់ឧបត្ថម្ភនោះទេ ប្រសិនបើអវត្តមានដោយមូលហេតុផ្សេង យើងនឹងចាត់វិធានការឱ្យបានតឹងតែង ។

នៅពេលចាប់ផ្តើមកម្មវិធីនេះ យើងនិងស្នើសុំអោយក្រុមគ្រួសារដែលចូលរួម ចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដើម្បីសងប្រាក់មកអោយកម្មវិធីវិញ ប្រសិនបើអ្នកចូលរួមកម្មវិធីនោះបោះបង់កម្មវិធីចោលក្នុងរយៈពេល ៦ ខែ ។ យើងប្រហែលជាមិនអាចទារយកប្រាក់នោះបានគ្រប់ចំនួនមកវិញទេ តែវាមានន័យថាជាការគាបសង្កត់មួយដែលអាចជួយបំពេញតំរូវការរបស់កម្មវិធីបាន ។ ដើម្បីធានាអោយបាននូវសុច្ចរិកភាពរបស់កម្មវិធី យើងនឹងធ្វើការត្រួតពនិត្យដល់ទីកន្លែង អង្កេតមិត្តរួមថ្នាក់របស់អ្នកចូលរួម ហើយនិងដាក់ទណ្ឌកម្មដល់លោកគ្រូអ្នកគ្រូដែលមើលការខុសត្រូវ ចំពោះការមិនស្មោះត្រង់ ដោយធ្វើការកាត់ប្រាក់ខែរបស់ពួកគេ។

បន្ថែមទៅលើកម្មវិធីសិក្សារបស់សាលា អ្នកចូលរួម **កម្មវិធីស្ត្រីគួរមានក្តីប្រាថ្នាខ្ពស់** នឹងត្រូវគេបង្រៀនភាសាអង់គ្លេស កុំព្យូទ័រ សិប្បកម្មដោយដៃ កសិកម្ម ហើយនិងវិជ្ជាជីវៈដទៃផ្សេងទៀត។

កម្មវិធីទាក់ទាញការយកចិត្តទុកដាក់របស់យើង នឹងមានការចុះដោយផ្ទាល់ពីបុគ្គលិកយើង ទៅតាមភូមិនានា និងជួបជាមួយគ្រួសារ នៃអ្នកចូលរួម កម្មវិធីស្ត្រីគួរមានក្តីប្រាថ្នាខ្ពស់ ដើម្បីបញ្ចាំងខ្សែភាពយន្តស្តីពីការជួយបង្រៀន ការផលិតសៀវភៅកំប្លែង និងខិតប័ណ្ណពតិមាន ហើយនិងសំភារៈសិក្សាដ៏ទៃទៀត ដើម្បីយកទៅបិទនៅលើក្តារខៀនព័តិមាននៅតាមភូមិ ។

យើងក៏មានផែនការនឹងប្រមូលលោកគ្រូអ្នកគ្រូដែលបង្រៀននៅតាមភូមិនានា ដែលយើងបញ្ជូនអោយទៅបង្រៀន ឬក៏បានប្រលងចេញពីកម្មវិធីមួយ ដែលអង្គការជំនួយជប៉ុន និងអាមេរិកបានឧបត្ថម្ភ នៅមណ្ឌលពន្លឺអនាគតកុមារ ដើម្បីមកចូលរួមសិក្ខាសាលា ដែលនៅទីនោះយើងនឹងផ្សព្វផ្សាយពីបញ្ហាជួញដូរស្ត្រី នៅកម្ពុជាហើយនិងវិធីសាស្ត្រក្នុងការធ្វើការសិក្សា ហើយនិងធ្វើរបាយការណ៍ ។ យើងនឹងអញ្ជើញអ្នកជំនាញការផ្នែកជួញដូរមនុស្សមកជួយយើងក្នុងការឧទ្ទេសនាមផ្នែកនេះ។

កម្មវិធីនេះ គឺមានបំណងដើម្បីការពារការជួញដូរស្ត្រីផង និងផ្តល់អំណោយដល់ស្ត្រីផង ដែលនៅពេលនេះស្ត្រីមានឋានៈទាបជាងគេ នៅក្នុងសង្គមកម្ពុជា ។ មួយឆ្នាំក្រោយមក យើងនឹងមានរបាយការណ៍លំអិតមួយដែលអាចធ្វើជាគំរូមួយ ដោយបាននាំស្ត្រីកម្ពុជាចំនួន ៥ម៉ឺន នាក់មកចូលរួមកម្មវិធីនេះ ហើយក៏ត្រូវអាចគេចំលងធ្វើតាមទូទាំងពិភពលោក។

ពីព្រោះថាសាលារៀននៅតាមជនបទរបស់យើង ភាគច្រើននឹងមានការភ្ជាប់អ៊ិនធឺណែត ដោយអាចផ្ញើនិងទទួលអ៊ីមែលបាន យើងនឹងក្លាយជាអង្គភាពមួយដែលមានសមត្ថភាព ក្នុងការអនុវត្តន៏កម្មវិធីមួយបែបនេះដោយជោគជ័យ ។

បើអស់លោកអ្នកចង់ក្លាយជាអ្នកឧបត្ថម្ភដល់នារីក្រីក្រម្នាក់ ដែលនឹងអាចចូលរៀនរយៈពេល១ឆ្នាំ លោកអ្នកអាចបរិច្ចាគជាថវិកាចំនួន ១២០$ ( ១៤ 000 យេន ) ជាមូលប្បទានប័ត្រ ឬមួយក៏ប្រាក់សុទ្ធ ហើយឈ្មោះរបស់អស់លោកអ្នក និងរូបថតនារីដែលលោកអ្នកឧបត្ថម្ភនោះ នឹងត្រូវបានដាក់ផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់យើងក្នុងពេលខាងមុខនេះ : GrilsBeAmbitious.org ។

មូលប្បទានប័ត្រអាចផ្ញើមកកាន់ American Assistance for Cambodia ដើម្បីទទួលបាននូវវិក្កយប័ត្រលើកលែងពន្ធដែលមានទឹកប្រាក់ចំនួន ១២០$ ។ AAfC ត្រូវបានចុះឈ្មោះក្នុងបញ្ជី ថាជាអង្គការដែលមិនយកផលកំរៃ នៅទីក្រុង Delaware ហើយនិងទទួលស្គាល់ដោយ IRS ថាជាអង្គការ ៥០១ ( C ) ៣ សំរាប់ការលើកលែងពន្ធ នៅសហរដ្ឋអាមេរិក ។ សំរាប់ព័ត៌មាន ដើម្បីទទួលបាននូវវិក្កយប័ត្រលើកលែងពន្ធនៅប្រទេសជប៉ុន សូមទាក់ទងមកយើងតាមរយៈអ៊ីមែល bernie@media.mit.edu

សូមផ្ញើមូលប្បទានប័ត្រជាប្រាក់ដុល្លាអាមេរិក ដែលទូទាត់ តាមធនាគារអាមេរិក អាចផ្ញើមកកាន់អាស័យដ្ឋាន :

Bernard Krisher
American Assistance for Cambodia
4-1-7-605 Hiroo
Shibuya-ku,Tokyo (150-0012) Japan

ឬមួយក៏លោកអ្នកផ្ញើប្រាក់មកគណនីរបស់ American Assistance for Cambodia នៅធនាគារ Ridgewood Savings Bank អាស័យដ្ឋាន Queen Blvd and 108 Street, Forest Hills, N.Y. 11375. គណនីលេខ ៦៤៨៨៩៩ ហើយនិងលេខតាមដានលេខ ២២៦០៧១០៣៣ ។ សូមបន្ថែម ១០$ សំរាប់ថ្លៃផ្ញើ ។ សូមជូនដំណឹងមកយើងខ្ញុំ ដោយផ្ញើអ៊ីមែល ហ្វាក់ ឬសំបុត្រ នៅពេលលោកអ្នកបានផ្ញើរួចហើយ ។

នៅក្នុងប្រទេសជប៉ុន តំលៃឧបត្ថម្ភប្រចាំឆ្នាំសំរាប់នារីក្រីក្រម្នាក់ដើម្បីអោយបានចូលរៀន គឺ ១៤ 000 យេន ។ សូមផ្ញើប្រាក់មកកាន់គណនី Cambodia Jizen Kikkin នៃធនាគារ Mitsui Sumitomo Bank អាស័យដ្ឋាន Hiroo Garden Hills Shucchojo, Futsu Yokin # 741291.

ការទូទាត់ក៏អាចធ្វើតាមរយៈ credit card, visa, masters ដោយបន្ថែម ៥ ដុល្លារ ហើយនិងតាមប្រពន្ធ័ Paypal ។ ពត៌មានលំអិតសូមផ្ញើអ៊ីមែលមកកាន់ : bernie@media.mit.edu